នស/រកត/០២០៦/០៩៧

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលមានសមាសភាព :

| | |
|---|---|
| ១-តំណាង នាយករដ្ឋមន្ត្រី | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៤-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| ៥-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

១២-អគ្គស្នងការនគរបាលជាតិ សមាជិក

១៣-អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ សមាជិក

១៤-មេបញ្ជាការកងទ័ពជើងគោក សមាជិក

១៥-មេបញ្ជាការកងទ័ពជើងទឹក សមាជិក

១៦-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៧-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១៨-អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាអគ្គលេខាធិការ សមាជិក

១៩-មេធាវីរាជរដ្ឋាភិបាល សមាជិក

២០-តំណាងគណបក្សសម រង្ស៊ី សមាជិក

២១-តំណាងគណបក្ស ហ៊្វុន ស៊ិន ប៉ិច សមាជិក

២២-តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធ សមាជិក

សមាសភាពជាក់ស្តែង នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២:** អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនេះ អាចមានអនុប្រធានមួយចំនួន តាមការចាំបាច់ ។

តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធ ជាសមាជិក នឹងត្រូវតែងតាំងដោយអនុក្រឹត្យ ។

**មាត្រា៣:** អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានបេសកកម្ម តួនាទី និងភារកិច្ច ដូចខាងក្រោម :

- ទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំ ផ្សព្វផ្សាយឱ្យសាធារណជនយល់ដឹងអំពីផលវិបាកបណ្តាលមកពីទំនាស់ដីធ្លី និងមានវិធានការដាក់វិន័យចំពោះជនល្មើស ដែលបានរំលោភបំពានលើបញ្ហាដីធ្លី ដោយខុសច្បាប់ជាធរមាន
- ទទួលសំណុំរឿងទំនាស់ដីធ្លីដែលហួសពីសមត្ថកិច្ចគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទំនាស់ដីធ្លី
- ស្វែងយល់ ស៊ើបអង្កេត និងដោះស្រាយទំនាស់ដីធ្លី
- ឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ នៃការដោះស្រាយទំនាស់ដីធ្លី ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤:** អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានអគ្គលេខាធិការដ្ឋានជាសេនាធិការ ។

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ។

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិក្រមសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

**មាត្រា៥:** អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទី និងភារកិច្ច ដូចតទៅ :

-ទទួល និងពិនិត្យសំណុំរឿង ពាក្យបណ្តឹង និងចុះស្វែងយល់ ស៊ើបអង្កេត ហើយធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេតពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លី ដើម្បីដាក់ជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ពិនិត្យសម្រេចតាមដំណាក់កាល និងករណីនីមួយៗ

-រៀបចំការប្រជុំ និងធ្វើកំណត់ហេតុអំពីអង្គប្រជុំរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-ចុះស្វែងយល់ ស៊ើបអង្កេត និងឃ្លាំមើលសកម្មភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការដោះស្រាយទំនាស់ដីធ្លី តាមការបញ្ជាណែនាំរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីទៅតុលាការ

-រៀបចំ និងតំកល់ទុកឯកសារពាក់ព័ន្ធទំនាស់ និងបណ្តឹងដីធ្លី

-រៀបចំសេចក្តីព្រាងរបាយការណ៍ អំពីសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តាមកាលកំណត់ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល

-ផ្សព្វផ្សាយជូនសាធារណជនអំពីលទ្ធផលនៃដំណោះស្រាយទំនាស់ដីធ្លី ដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បានដោះស្រាយចប់ជាស្ថាពរ ។

**មាត្រា៦:** អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានទីតាំងនៅទីស្តីការគណៈ-រដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយនិងការចំណាយក្នុងកិច្ច-ដំណើរការ ជាបន្ទុកថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៧:** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៨:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០២០៦-១០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

លេខ: ១០០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]